**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

ថ្ងៃសៅរ៍ ៥រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីករណីមន្ត្រីស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា លើកឡើងថា ក្រុមហ៊ុនចិនមួយចំនួនប្រើប្រាស់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បញ្ជូនទំនិញពីចិនទៅសហរដ្ឋអាមេរិក ដើម្បីគេចវេសពីការបង់ពន្ធ ឬបង់ពន្ធទាប

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា៖ កាលពីពេលថ្មីៗកន្លងទៅនេះ សារព័ត៌មានរ៉យទ័រ (Reuters) និងវិទ្យុអាស៊ីសេរី (RFA) បានដកស្រង់សំដីមន្ត្រីនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា **លោក អេរិន ឡាតជេស** (Arend Zwartjes) ដែលបានអះអាងថា នាយកដ្ឋានសន្តិសុខជាតិអាមេរិក បានត្រួតពិនិត្យរកឃើញ និងពិន័យទៅលើក្រុមហ៊ុនចិនមួយចំនួនមានទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដែលបានបំពានបំរាមគយរបស់អាមេរិក ដោយថា ក្រុមហ៊ុនទាំងនោះបានបញ្ជូនទំនិញពីចិន មានដូចជា អាស៊ីតអាមីណូ ម្សៅអាហារធ្វើពីគ្រាប់ធញ្ញជាតិ (ពោតស្រូវ ឬដំឡូង) និងបំពង់ដែកថែប។ល។ ទៅសហរដ្ឋអាមេរិក តាមរយៈប្រទេសកម្ពុជា ដើម្បីគេចពីការបង់ពន្ធ ឬបង់ពន្ធក្នុងកម្រិតលើកលែង។

ទាក់ទងនឹងករណីនេះ បន្ទាប់ពីបានចាត់មន្ត្រីជំនាញចុះស្រាវជ្រាវរួចមក ក្រសួងពាណិជ្ជកម្ម សូមបញ្ជាក់ថា៖ ការលើកឡើងរបស់មន្ត្រីស្ថានទូតអាមេរិក ពុំមានមូលដ្ឋានច្បាស់លាស់ឡើយ ពោលគឺ ផ្ទុយពីការអនុវត្តជាក់ស្តែង ព្រោះថាក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មិនមានក្រុមហ៊ុនផលិតម្សៅអាហារធ្វើពីគ្រាប់ធញ្ញជាតិ និងបំពង់ដែកថែបទេ។ ចំពោះផលិតផលអាស៊ីដអាមីណូ កន្លងទៅក្រុមហ៊ុន INFINITE MANUFACTURING CO., LTD. ដែលបានទទួលច្បាប់អនុញ្ញាតឲ្យវិនិយោគត្រឹមត្រូវពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) តាំងពីដើមខែកុម្ភៈ ឆ្នាំ២០១៥ បានធ្វើប្រតិបត្តិការផលិតកម្ម និងនាំចេញ រហូតដល់ខែសីហា ឆ្នាំ២០១៧។ ប៉ុន្តែចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន ក្រុមហ៊ុនមួយនេះពុំដំណើរការផលិតកម្ម និងសកម្មភាពនាំចេញឡើយ ។

ក្រសួងពាណិជ្ជកម្ម ក៏សូមជម្រាបផងដែរថា តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ គឺជាតំបន់សេដ្ឋកិច្ច និងពាណិជ្ជកម្មពហុបំណង ដែលប្រមូលផ្តុំទៅដោយសហគ្រាសចិន កម្ពុជា អាមេរិក ជប៉ុន បារាំង កូរ៉េខាងត្បូង អៀរឡង់ វៀតណាម និងថៃ ជាដើម។ល។ ហើយមានផលិតនូវទំនិញចម្រុះ ដូចជា៖ វាយនភណ្ឌ សម្លៀកបំពាក់ កាបូប និងផលិតផលស្បែក និងឧបករណ៍ផ្សេងៗផងដែរ។

ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តន៍តាមនីតិវិធីច្បាស់លាស់ ពោលគឺ ផលិតកម្មត្រូវអនុលោមតាមវិធានប្រភពដើមទំនិញ រីឯការនាំចូលវត្ថុធាតុដើម និងការនាំចេញផលិតផលសម្រេច ត្រូវបានកត់ត្រាត្រឹមត្រូវ ព្រមទាំងមានតម្កល់លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផង។ ដើម្បីអាចប្រតិបត្តិការផលិតកម្មរបស់ខ្លួនបាន ក្រុមហ៊ុនត្រូវ ៖

- **មានអាជ្ញាប័ណ្ណវិនិយោគ និងបានចុះបញ្ជីត្រឹមត្រូវ,**
- **មានទីតាំង និងមូលដ្ឋានផលិតកម្មច្បាស់លាស់ ដើម្បីបម្រើការផលិត កែច្នៃ និងនាំចេញ,**
- **ស្នើសុំបញ្ជីមេ (Master List) ដែលរាយលម្អិតនូវប្រភេទវត្ថុធាតុដើមត្រូវនាំចូល ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចៀសវាងការនាំចូលផលិតផលសម្រេច,**
- **រាល់វត្ថុធាតុដើមដែលនាំចូល ត្រូវបានផ្ទៀងផ្ទាត់ជាមួយបញ្ជីមេ និងឆ្លងកាត់ការត្រួតពិនិត្យជាក់ស្តែងរបស់ អាជ្ញាធរគយ និងរដ្ឋាករកម្ពុជា។**

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាទទួលជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង **ឯកឧត្តម ស៊ាង ថៃ** អនុរដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងពាណិជ្ជកម្ម តាមរយៈទូរស័ព្ទ ០១២ ៣១៣ ៣៣៣ ឬអ៊ីម៉ែល seangthay@yahoo.com។

សូមអរគុណ!